**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានការងារ**

**នាយកដ្ឋានអធិការកិច្ចការងារ**

លេខ៖២៦៥ ក.ប/អក/អធក/ក្រុមទី១២

# លិខិតដាក់កំហិត

យើង **ប៉ា សំខន្សាន:** អត្តលេខ **០០០៤០** ជាអធិការការងារ និងជាមន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបាននីតិសម្បទាក្នុងការពិនិត្យអំពើល្មើសច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យការងារ

**កម្មវត្ថុ** ៖ ការដាក់កំហិតស្តីពីការអនុវត្តបែបបទស្តីពីសហគ្រាស លក្ខខណ្ឌទូទៅនៃការងារ លក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ លក្ខខណ្ឌនៃបេឡាជាតិសន្តិសុខសង្គម និងលក្ខខណ្ឌ ទំនាក់ទំនងវិជ្ជាជីវៈ។

**យោង** ៖ -ច្បាប់ស្តីពីការងារ, ច្បាប់ស្តីពីសហជីព, ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា, ច្បាប់ស្តីពីរបបសន្តិសុខសង្គម និងបទប្បញ្ញត្តិជាធរមានក្នុងវិស័យការងារ

-របាយការណ៍ស្តីពីអធិការកិច្ចការងារពិសេស ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០២២

សម្រេចដាក់កំហិតចំពោះ **លោក លោកស្រីជាម្ចាស់ ឬនាយករោចក្រ សហគ្រាស កាត់ដេរសំលៀកបំពាក់ (ឌីណា អមរា)** ដូចខាងក្រោម៖

ក. ត្រូវបំពេញបែបបទស្តីពីសហគ្រាសឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីរបបសន្តិសុខសង្គម យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២៣ ជាកំហិត ដូចខាងក្រោម៖

១. (២.២) ត្រូវរៀបចំសៀវភៅបញ្ជីប្រចាំសហគ្រាស ឱ្យបានត្រឹមត្រូវ

២. (២.២) ត្រូវរៀបចំសៀវភៅបើកប្រាក់ ឬបញ្ជីប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រឱ្យបានត្រឹមត្រូវ

៣. (២.២) ត្រូវរក្សាទុកសៀវភៅបើកប្រាក់ ឬបញ្ជីប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រឱ្យបានត្រឹមត្រូវ

៤. (២.២) ត្រូវផ្តល់សៀវភៅបើកប្រាក់
ឬបញ្ជីប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រឱ្យអធិការការងារត្រួតពិនិត្យតាមមុខងារឱ្យបានត្រឹមត្រូវ

ខ. ត្រូវអនុវត្តលក្ខខណ្ឌទូទៅនៃការងារឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ចាប់ពីពេលនេះតទៅ មានដូចជា៖

១. (៦.១.១៣) ត្រូវផ្តល់បង្កាន់ដៃបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត មុនពេលបើកប្រាក់ឈ្នួលឱ្យបានត្រឹមត្រូវ

២. (៦.៤.៤) ត្រូវផ្តល់ការឈប់សម្រាកពិសេសជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៣. (៦.៤.៤) ត្រូវឱ្យកម្មករនិយោជិតធ្វើការសងថ្ងៃឈប់សម្រាកពិសេសឱ្យបានត្រឹមត្រូវ

៤. (៦.៤.៤) ត្រូវផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងនៅពេលឈប់សម្រាកពិសេសឱ្យបានត្រឹមត្រូវ

៥. (៦.៤.៥) ត្រូវផ្តល់ការឈប់សម្រាកប្រចាំឆ្នាំដោយមានប្រាក់ឈ្នួលជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

៦. (៦.៤.៥) ត្រូវផ្តល់ប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ
៧. (៦.៤.៥) ត្រូវផ្តល់ប្រាក់ឈ្នួលនិង
អត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិតនៅមុនពេលឈប់សម្រាកប្រចាំឆ្នាំឱ្យបានត្រឹមត្រូវ
៨. (៦.៤.៦) ត្រូវផ្តល់ការឈប់សម្រាកដោយជំងឺជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវ

គ.ត្រូវអនុវត្តលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ចាប់ពីពេលនេះតទៅ មានដូចជា៖

ឃ. ត្រូវអនុវត្តលក្ខខណ្ឌនៃរបបសន្តិសុខសង្គម ឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម ចាប់ពីពេលនេះតទៅ មានដូចជា៖

ង. ត្រូវអនុវត្តលក្ខខណ្ឌទំនាក់ទំនងវិជ្ជាជីវៈ ឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព ចាប់ពីពេលនេះតទៅ មានដូចជា៖

ត្រូវចាត់ទុកថាបានប្រព្រឹត្តអំពើល្មើស ក្នុងករណី **លោក លោកស្រី** មិនបានអនុវត្តតាមការដាក់កំហិតខាងលើ។ អធិការការងារនឹងជាកតពិន័យ និងចាត់វិធានការតាមផ្លូវច្បាប់ប្តឹងទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន និងរាល់ការចំណាយជាបន្ទុករបស់ **លោក លោកស្រី**។

សូម **លោក លោកស្រី** ជ្រាប និងអនុវត្តឱ្យបានត្រឹមត្រូវ។

ថ្ងៃ ១៣ កើត ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦.
រាជធានីភ្នំពេញ ថ្ងៃទី ២១ខែ ធ្នូ ឆ្នាំ២០២២
**អធិការការងារ**

បានទទួល
សម ណាត
ម្ចាស់

**ប៉ា សំបឡុនៈ**